សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា (ស.ទ.ក)
Cambodian Water Supply Association (C.W.A)

# កំណត់ហេតុ
# កិច្ចប្រជុំថ្នាក់តំបន់

ថ្ងៃសុក្រ ទី៦ ខែមិថុនា ឆ្នាំ២០២៥ វេលាម៉ោង ៨:០០ព្រឹក ដល់ម៉ោង ៥.០០ល្ងាច សមាគមបានសហការជាមួយ សាលាខេត្ត ខេត្តសៀមរាប រៀបចំកិច្ចប្រជុំថ្នាក់តំបន់ នៅសណ្ឋាគារ អង្គរប៉ារាឌី ខេត្តសៀមរាប សម្រាប់ប្រតិបត្តិករអញ្ជើញមកពីខេត្តទាំង៦ រួមមាន៖ ខេត្តបន្ទាយមានជ័យ ឧត្តរមានជ័យ ព្រះវិហារ កំពង់ធំ កណ្តាល និងសៀមរាប។ កិច្ចប្រជុំនេះមានអ្នកចូលរួមសរុបចំនួន ១០០នាក់(ស្រី ១៧នាក់) រួមមាន៖ ១). អភិបាលរងខេត្ត ២). ថ្នាក់ដឹកនាំ និងមន្ត្រីនៃមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (ឧ.វ.ប.ន.) ខេត្តសៀមរាប បន្ទាយមានជ័យ កំពង់ធំ ព្រះវិហារ ឧត្តរមានជ័យ ៣). ថ្នាក់ដឹកនាំ និងមន្ត្រី នៃមន្ទីរធនធានទឹក និងឧតុនិយម ខេត្តសៀមរាប និងឧត្តរមានជ័យ ៤). ថ្នាក់ដឹកនាំ និងមន្ត្រី នៃមន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តសៀមរាប កំពង់ធំ និងបន្ទាយមានជ័យ ៥). ថ្នាក់ដឹកនាំ និងមន្ត្រី នៃមន្ទីរសាធារណៈការ និងដឹកជញ្ជូន ខេត្តសៀមរាប និងកំពង់ធំ ៦). ថ្នាក់ដឹកនាំ និងមន្ត្រី នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តសៀមរាប ៧). ថ្នាក់ដឹកនាំ និងមន្ត្រី នៃមន្ទីររ៉ែ និងថាមពល ខេត្តសៀមរាប ៨). លោក លោកស្រី ថ្នាក់ដឹកនាំ និងសមាជិកក្រុមប្រឹក្សាភិបាល បុគ្គលិកសមាគម ៩). ប្រតិបត្តិករអញ្ជើញមកពីខេត្តទាំង ៦ខាងលើ និង ១០). ឧបត្ថម្ភគាំទ្រកម្មវិធីរួមមាន៖ អង្គការ Water.org, SME Bank, ACLEDA Bank, FTB Bank, មីក្រូហិរញ្ញវត្ថុ AMK, ក្រុមហ៊ុន E-Water, ក្រុមហ៊ុន KUBOTA Cambodia, ក្រុមហ៊ុន Techzone Plus, ក្រុមហ៊ុន Khmer Angkor Plastic, ក្រុមហ៊ុន KCRI International, ក្រុមហ៊ុន Water Partner Cambodia, ក្រុមហ៊ុន Phnom Penh Plastic Product, ក្រុមហ៊ុន UPG Pipe និង ក្រុមហ៊ុន TCU។

កិច្ចប្រជុំថ្នាក់តំបន់នេះមានគោលដៅ«**ធ្វើការរួមគ្នាដើម្បីជំរុញសេវាកម្មផ្គត់ផ្គង់ទឹកស្អាតឱ្យសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ២០៣០។**» និង មានគោលបំណងជាក់លាក់ចំនួនបីដូចខាងក្រោម៖

១. ស្តាប់សំឡេងរបស់សមាជិក និងស្វែងរកដំណោះស្រាយជូនសមាជិក
២. បង្កើនទំនាក់ទំនងជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិ និងមន្ទីរពាក់ព័ន្ធ សមាជិកសមាគម និងដៃគូអភិវឌ្ឍន៍នានា
៣. ធ្វើបច្ចុប្បន្នភាពអំពីសមាគម ច្បាប់គតិយុត្តនានាទាក់ទងទៅនឹងវិស័យទឹកស្អាត និងការចែករំលែកចំណេះដឹង បទពិសោធន៍ ព័ត៌មាន និងបច្ចេកវិទ្យាថ្មីៗ។*សូមភ្ជាប់ជូន របៀបវារៈនៃកិច្ចប្រជុំថ្នាក់តំបន់។*

Final Program_kh (1).pdf

## ១. កម្មវិធីបើក

**លោក ឡេង ឌៀវ ប្រធានសមាគម** បានស្វាគមន៍ និងថ្លែងអំណរគុណ **លោក អ៊ុំ គឹមលាង** អភិបាលរងនៃគណៈអភិបាលខេត្តសៀមរាប និងជាតំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តសៀមរាប** ដែលបានសហការរៀបចំកិច្ចប្រជុំនេះបានយ៉ាងល្អ និងសូមអរគុណ លោក លោកស្រី ជាប្រធាន ឬតំណាង មន្ទីរពាក់ព័ន្ធទាំងអស់ដែលបានចំណាយពេលវេលាដ៏មមាញឹកអញ្ជើញចូលរួមកិច្ចប្រជុំនេះ។ **លោក ឡេង ឌៀវ** បានបញ្ជាក់ជូនថា សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា គឺជាសមាគមអព្យាក្រឹត មិនស្វែងរកប្រាក់កម្រៃ មិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ និងមិនធ្វើនយោបាយ ។ សមាគមបម្រើឱ្យផលប្រយោជន៍សមាជិក និងផលប្រយោជន៍សាធារណៈតាមលទ្ធភាពដែលសមាគមអាចចូលរួមបាន។ ទស្សនវិស័យសមាគមគឺ «***ចង់ឃើញប្រជាពលរដ្ឋ***

*កម្ពុជានៅគ្រប់តំបន់ក្នុងព្រះរាជាណាចក្រកម្ពុជា ទទួលបានសេវាទឹកស្អាត និង អនាម័យដែលមានគុណភាពស្របតាមស្តង់ដាទឹកស្អាតថ្នាក់ជាតិ»។* ទស្សនវិស័យនេះស្របទៅនឹងគោលនយោបាយ របស់រាជរដ្ឋាភិបាលដែលបានកំណត់ថា «ត្រឹមឆ្នាំ២០៣០ សម្រេចបាននូវទឹកបរិភោគប្រកបដោយសុវត្ថិភាព និងថ្លៃសមរម្យសម្រាប់មនុស្សគ្រប់គ្នា»។

ដើម្បីសម្រេចបាននូវទស្សនវិស័យខាងលើ សមាគម ក្រោមកិច្ចគាំទ្រពីកម្មវិធី CAPRED ប្រទេសអូស្ត្រាលី បានគាំទ្រដល់កិច្ចសហប្រតិបត្តិការរវាង សមាគមទឹកអូស្ត្រាលី (AWA) និងសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រ សម្រាប់ឆ្នាំ២០២៥-២០៣០ ដែលផ្តោតលើយុទ្ធសាស្ត្រសំខាន់រួមមាន៖

១. ពង្រឹងសមត្ថភាពវិជ្ជាជីវៈ និងនិរន្តរភាពសមាជិក ដើម្បីផ្តល់សេវាទឹកស្អាតប្រកបដោយការទទួលខុសត្រូវ រួមចំណែកដល់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា

២. បង្កើនគុណភាពនៃការចូលរួមរបស់សមាជិក និងសេវាកម្មផ្តោតលើគុណតម្លៃរបស់សមាជិក

៣. លើកកម្ពស់ភាពជាតំណាងសមាជិកប្រកបដោយប្រសិទ្ធភាព និងតស៊ូមតិដោយផ្អែកលើភស្តុតាងសម្រាប់សមាជិក និងនិរន្តរភាពនៃវិស័យ។

៤. ពង្រឹងសមត្ថភាពស្ថាប័ន និងនិរន្តរភាពហិរញ្ញវត្ថុសមាគមដើម្បីផ្តល់សេវាកម្មប្រកបដោយប្រសិទ្ធភាព

លោកក៏បានថ្លែងអំណរគុណចំពោះអង្គការ Water.org និងក្រុមហ៊ុនទាំង១៣ ដែលបានសហការឧបត្ថម្ភគាំទ្រកិច្ចប្រជុំថ្នាក់តំបន់នៅខេត្តសៀមរាបនេះ។

សុន្ទរកថាបើកអង្គប្រជុំដោយ **លោក អ៊ឹង គីមលាង** អភិបាលរងនៃគណៈអភិបាលខេត្តសៀមរាប លោកបានលើកឡើងថា ក្នុងវិស័យទឹកស្អាត សមាគមមានតួនាទីសំខាន់ណាស់ក្នុងការសម្របសម្រួលសកម្មភាព និងការបង្រួបបង្រួមគ្នា។ ខ្ញុំយល់ស្របតាមប្រធានសមាគម ដែលបានលើកឡើងថា សមាគមពិតជាមានអព្យាក្រិតភាពក្នុងការអនុវត្តការងាររបស់ខ្លួន។ លោកបានបន្ថែមថា នៅក្នុងខេត្តសៀមរាប ស្រះ បឹង និងត្រពាំងទឹកមានចំនួនច្រើន និងតម្រូវឱ្យមានការស្តារឡើងវិញ ខេត្តកំពុងត្រួតពិនិត្យលើការងារស្តារស្រះ បឹង និងត្រពាំងទាំងនោះដើម្បីមានទឹកជូនប្រជាពលរដ្ឋប្រើប្រាស់គ្រប់គ្រាន់។ ថ្ងៃនេះជាកិច្ចប្រជុំដ៏មានសារៈសំខាន់ សូមបងប្អូនទាំងអស់លើកឡើងនូវគ្រប់បញ្ហាដែលបានជួបប្រទះដើម្បីស្វែងរកដំណោះស្រាយរួមគ្នាឱ្យបានប្រសើរ។ ខេត្តសៀមរាបមានទឹកសហគមន៍ចំនួន៤៩ ដែលជួយគាំទ្រដោយអង្គការដៃគូ ជាគោលការណ៍ចំនួនតំណទឹកសហគមន៍ក្រោម ៥០០តំណ ស្ថិតក្រោមសមត្ថកិច្ចរបស់មន្ទីរអភិវឌ្ឍន៍ជនបទ បើលើសពី ៥០០តំណឡើង ត្រូវផ្គត់ផ្គង់ដោយវិស័យឯកជនដែលត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួង/មន្ទីរ ឧ.វ.ប.ន.។ សូមបញ្ជាក់ជូនថា អាជ្ញាបណ្ណមិនមែនយកមកទុកលក់ទេ គឺបានមកហើយត្រូវតែធ្វើដើម្បីជួយផ្គត់ផ្គង់ទឹកស្អាតជូនដល់ប្រជាពលរដ្ឋឱ្យបានគ្រប់គ្រាន់។ នៅកម្ពុជាយើងការប្រើប្រាស់ទឹកជាមធ្យមក្នុងមួយថ្ងៃ ១៥០លីត្រសម្រាប់មនុស្សម្នាក់នៅរាជធានីភ្នំពេញ និងនៅខេត្តសៀមរាប ១២០លីត្រសម្រាប់មនុស្សម្នាក់។ ក្នុងនាមរដ្ឋបាលខេត្ត ខ្ញុំសូមផ្តាំផ្ញើ និងលើកទឹកចិត្តដល់អង្គពិធីទាំងមូលថា សូមពិភាក្សាឱ្យច្បាស់អំពីបញ្ហាប្រឈមរបស់សហគមន៍ និងដំណោះស្រាយ។ រវាងការចេញអាជ្ញាបណ្ណ និងទឹកសហគមន៍ ការផ្ទេរត្រូវធ្វើឱ្យបានសមរម្យ។ យើងដឹងថា អង្គការដៃគូមិននៅយូរទេ យើងមិនត្រូវបណ្តោយឱ្យកម្មវិធីទឹកស្អាតចប់តាមគម្រោងរបស់អង្គការនោះទេ។ អ្វីដែលខ្ញុំចង់បាននោះ គឺការលើកឡើងឱ្យចំៗលើ **បញ្ហាប្រឈម ដំណោះស្រាយ និងសំណូមពរ**។ ជាចុងក្រោយលោកក៏បានប្រកាសបើកកិច្ចប្រជុំថ្នាក់តំបន់ចាប់ពីពេលនេះតទៅ។

## ២. បទបង្ហាញ អំពីគោលបំណងនៃកិច្ចប្រជុំ និងបច្ចុប្បន្នភាពអំពីសមាគម និងបញ្ហាប្រឈមរបស់សមាជិក

**លោក លឹម មិញ** បានធ្វើបទបង្ហាញពីគោលបំណងនៃកិច្ចប្រជុំ និងបច្ចុប្បន្នភាពអំពីសមាគម និងបញ្ហាប្រឈមរបស់សមាជិក។ លោកក៏បានជម្រាបជូនអង្គពិធីអំពីគុណតម្លៃ ផែនការយុទ្ធសាស្ត្ររបស់សមាគម ២០២៥-២០៣០ អំពីសមាជិក និងការបង់វិភាគទានសមាជិកភាព និងបានថ្លែងអំណរគុណចំពោះសមាជិកដែលបានបង់ប្រាក់សមាជិក

ភាពទៀងទាត់ និងសំណូមពរដល់សមាជិកដែលមិនទាន់បានបង់ សូមចាប់ផ្តើមបង់សមាជិកភាពមកសមាគម។ *សម្រាប់ព័ត៌មានលម្អិតមាននូវក្នុងស្លាយបទបង្ហាញ។*

01-About_CWA_2025.pdf

## ៣. ការពិភាក្សាក្រុមប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន អំពីបញ្ហាប្រឈម

អ្នកចូលរួមទាំងអស់ត្រូវបានចែកជាក្រុមពិភាក្សាតាមគុនីមួយៗ និងចែករំលែកលទ្ធផលពិភាក្សាដល់ក្រុមធំដូចខាងក្រោម៖

**បញ្ហាប្រឈម**

- **ប្រភពទឹក**
  - ខ្វះប្រភពទឹក
  - ទឹកក្រោមដីមានកំបោរច្រើន
- **ការខូចខាតបណ្តាញទឹកស្អាត**
  - ការជូនដំណឹងអំពីការអភិវឌ្ឍន៍ផ្លូវថ្នល់មកខាងមន្ទីរ ឧ.វ.ប.ន. និងប្រតិបត្តិករ មានការយឺតយ៉ាវ
  - ធ្វើផ្លូវដាច់បំពង់ទុយោ
  - ប្រជាជន និងអ្នកម៉ៅការជីកធ្លាយបំពង់ទុយោទឹកស្អាត
  - ការធ្វើផ្លូវ លូ និងបណ្តាញទឹកកខ្វក់ប៉ះបណ្តាញទឹកស្អាត និងមិនទទួលបានសំណង
- **ចំណេះដឹងប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋាន**
  - ចំណេះដឹង និងព័ត៌មានទាក់ទងនឹងទឹកស្អាត (ច្បាប់ នីតិវិធី ការទទួលខុសត្រូវ)
  - ប្រជាជនមានចំណេះដឹងនៅមានកម្រិតអំពីសារៈប្រយោជន៍នៃការប្រើប្រាស់ទឹកស្អាត
  - ប្រជាពលរដ្ឋមានប្រភពទឹកផ្សេងៗសម្រាប់ប្រើប្រាស់
  - ការយល់ដឹងរបស់អាជ្ញាធរមូលដ្ឋាន
- **ចំណេះដឹងរបស់ប្រតិបត្តិករ**
  - ចំណេះដឹងផ្នែកបច្ចេកទេសនៅមានកម្រិត
- **សកម្មភាពលក់ទឹកក្នុងតំបន់អាជ្ញាបណ្ណ (ខុសច្បាប់)**
  - មានការលក់ទឹកឆៅក្នុងតំបន់សេវា

**សំណូមពរ**

- សុំឱ្យមានសំណងសមរម្យលើផលប៉ះពាល់ទុយោទឹកស្អាត
- សូមឱ្យមានការជូនដំណឹងមកប្រតិបត្តិករជាមុន អំពីគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនានា
- មន្ទីរឧ.វ.ប.ន.ធ្វើបទបង្ហាញអំពីនិតិវិធីនៃការស្នើសុំ និងការទទួលបានអាជ្ញាបណ្ណ ជូនដល់មន្ទីរ និងអាជ្ញាធរពាក់ព័ន្ធ។

**សំណួរ**

- តើមានវិធីណាដែលល្អប្រសើរក្នុងការលាងសម្អាតបំពង់មេឱ្យបានស្អាតល្អ?
- តើត្រូវធ្វើដូចម្តេចដើម្បីកាត់បន្ថយកំបោរនៅក្នុងប្រភពទឹក (ទឹកអណ្តូង)?

## ៤. បទបង្ហាញអំពីបច្ចុប្បន្នភាពការផ្គត់ផ្គង់ទឹកស្អាត បញ្ហាប្រឈម និងដំណោះស្រាយ/អនុសាសន៍

**៤.១. មន្ទីរ ឧ.វ.ប.ន. ខេត្តសៀមរាប**

ទិន្នន័យឆ្នាំ២០២៤ មានប្រតិបត្តិករចំនួន ១៤ ក្នុងនោះ ១០ប្រតិបត្តិករបានផលិត និងចែកចាយទឹកស្អាត និង ៤ប្រតិបត្តិករទើបទទួលបានអាជ្ញាបណ្ណ និងកំពុងដំណើរការសាងសង់ហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត។ ក្នុងចំណោមប្រតិបត្តិករ១០ មានតែ៩ប្រតិបត្តិករប៉ុណ្ណោះដែលទទួលបានវិញ្ញាបនបត្រប្រតិបត្តិការ (Certificate of Operation)។ *សម្រាប់ព័ត៌មានលម្អិតមាននូវក្នុងស្លាយបទបង្ហាញ។*

Presentation-DISTI-SRP.pdf

**បញ្ហាប្រឈម**

- ខ្វះរចនាសម្ព័នគ្រប់គ្រងការងារ និងតួនាទីភារកិច្ចបុគ្គលិកបម្រើការងារឱ្យបានច្បាស់លាស់
- បញ្ជីការគណនេយ្យ និងហិរញ្ញវត្ថុនៅមានកម្រិត។
- កម្រិតចំណេះដឹង និងជំនាញលើវិស័យទឹកស្អាតនៅមានកម្រិត ត្រូវការបណ្តុះបណ្តាលបន្ថែម(ការគ្រប់គ្រងច្បាប់ គណនេយ្យ ហិរញ្ញវត្ថុ ទីផ្សារ ជំនាញបច្ចេកទេសការផលិតទឹកស្អាតជាដើម)។
- ការអនុវត្តតាមផែនការសិក្សាសមិទ្ធិលទ្ធភាពពុំទាន់បានល្អទៅតាមផែនការកំណត់។
- ប្រតិបត្តិករមួយចំនួនតូច អនុវត្តយកថ្លៃទឹកខុសពីប្រកាសអនុញ្ញាត។
- ពុំទាន់មានបន្ទប់ពិសោធន៍កម្រិតបឋម(ស្តង់ដា)សម្រាប់តាមដានគុណភាពទឹកតាមការណែនាំរបស់ក្រសួង។
- ប្រភពទឹកសម្រាប់ផលិតនៅមានកម្រិត ពុំមាននិរន្តរភាព១០០% អាចនឹងប្រឈមខ្វះទឹកនាពេលខាងមុខ។
- ប្រព័ន្ធផលិតកម្មទឹកស្អាតរបស់ប្រតិបត្តិករមួយចំនួននៅមានកម្រិត លើអនាម័យ និងសុវត្ថិភាព។ ត្រូវបន្តកែលម្អឈានទៅកម្រិតទឹកស្អាតស្តង់ដាជាតិ។
- ប្រតិបត្តិករមួយចំនួនតូចនៅមានការយឺតយ៉ាវក្នុងការផ្តល់របាយការណ៍នានាជូនមន្ទីរ ជាហេតុធ្វើឱ្យមន្ទីររៀបចំរបាយការណ៍ជូនក្រសួង និងរដ្ឋបាលខេត្តមានការលំបាក។

**អនុសាសន៍៖ ប្រតិបត្តិករត្រូវ**

- រៀបចំបញ្ជីការគណនេយ្យ និងហិរញ្ញវត្ថុឱ្យបានច្បាស់លាស់សម្រាប់អនាគតងាយស្រួលទទួលឥណទានពីធនាគារ។
- បច្ចុប្បន្នភាពពង្រីកបណ្តាញត្រូវជូនដំណឹងដល់មន្ទីរ និងភ្ជាប់ជាមួយផែនទីពង្រីកបណ្តាញ។
- សិក្សាប្រភពទឹកដែលមានស្រាប់ និងផែនការពង្រីកបន្ថែមដើម្បីធានានិរន្តរភាពក្នុងការផ្គត់ផ្គង់ទឹកស្អាត
- បណ្តុះបណ្តាលចំណេះដឹងបន្ថែមលើការងារផលិតទឹកស្អាតដើម្បីឈានដល់ការផលិតទឹកស្អាតកម្រិតស្តង់ដាថ្នាក់ជាតិ។
- អនាម័យសម្អាតទីធ្លា និងកន្លែងផលិតកម្មជាប្រចាំ ជៀសវាងការផលិតចែកចាយទឹកមិនស្អាតដល់អ្នកប្រើប្រាស់
- ពិនិត្យលទ្ធភាពរៀបចំបន្ទប់ពិសោធន៍/ឧបករណ៍វិភាគគុណភាពទឹក តាមដានការពិនិត្យគុណភាពជាប្រចាំ ធ្វើការព្យាសកម្ម (calibration) លើឧបករណ៍ធ្វើតេស្តគុណភាព ដើម្បីធានាឱ្យបាននូវសុក្រឹត្យភាពនៃឧបករណ៍ និងកត់ត្រាទុកនូវទិន្នន័យនៃការធ្វើតេស្តឱ្យបានទៀងទាត់ ដើម្បីផលិតទឹកឱ្យមានគុណភាពល្អស្របតាមស្តង់ដាថ្នាក់ជាតិ។
- អនុវត្តន៍ថ្លៃលក់ទឹកស្អាតស្របតាមប្រកាសដែលបានកំណត់។

**៤.២. មន្ទីរ ឧ.វ.ប.ន. ខេត្តកំពង់ធំ**

ក្នុងខេត្តកំពង់ធំមានប្រតិបត្តិករទឹកស្អាតចំនួន ២៩ស្ថានីយ មានប្រកាស ២៧ (ប្រតិបត្តិករឯកជន ២៥ និងរដ្ឋាករសាធារណៈ ២)។ ក្នុងចំណោម ២៩ស្ថានីយ មានប្រតិបត្តិករកំពុងផ្គត់ផ្គង់ទឹកស្អាតមានចំនួន ១៨ស្ថានីយ ៤ស្ថានីយកំពុងសាងសង់ និង៥ស្ថានីយមិនទាន់សាងសង់ ដោយឡែក ២ស្ថានីយបានស្នើសុំអាជ្ញាបណ្ណទៅក្រសួង។ សម្រាប់ *ព័ត៌មានលម្អិតមាននូវក្នុងស្លាយបទបង្ហាញ។*

Presentation-DISTI-KPT.pdf

**បញ្ហាប្រឈម**

- ប្រភពទឹកត្រូវបានរីងស្ងួតដោយសារបម្រែបម្រួលអាកាសធាតុ
- ការមិនស្តារប្រឡាយឡើងវិញ ដែលនាំឱ្យខ្វះប្រភពទឹក
- ប្រតិបត្តិករមួយចំនួនមានចំណេះដឹងនៅមានកម្រិតទាក់ទងនឹងវិស័យទឹកស្អាត
- ការពង្រីកហេដ្ឋារចនាសម្ព័ន្ធ(ផ្លូវ) ដែលប៉ះពាល់ដល់បណ្តាញទឹកស្អាត
- ប្រជាពលរដ្ឋពុំសូវយល់ដឹងអំពីការប្រើប្រាស់ទឹកស្អាត ដែលធ្វើឱ្យកំណើនតំណយឺត
- ស្ថានីយមួយចំនួនប្រើប្រាស់បុគ្គលិកតិចពេក ធ្វើឱ្យការងារមានការយឺតយ៉ាវ
- ទំនាក់ទំនងរវាងប្រតិបត្តិករ និងអាជ្ញាធរមូលដ្ឋាននៅមានកម្រិត
- ប្រតិបត្តិករមួយចំនួនពុំទាន់បានដាក់បណ្តាញពេញផ្ទៃសេវា

**ដំណោះស្រាយ៖ ប្រតិបត្តិករត្រូវ**

- បង្កើនការយកចិត្តទុកដាក់ក្នុងការថែរក្សាប្រភពទឹកដូចជា ជីកស្រះបន្ថែម និងជីកអណ្តូង
- ធ្វើការទំនាក់ទំនងជាមួយស្ថាប័នពាក់ព័ន្ធដើម្បីពន្លឿនការស្តារប្រឡាយ ក៏ដូចជាស្វែងរកប្រភពទឹកផ្សេងទៀត(បើមាន)។
- ជម្រុញប្រតិបត្តិករទឹកស្អាតបង្កើនសមត្ថភាព(ការចូលរួមជាមួយសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា)
- ត្រូវផ្សព្វផ្សាយអំពីសារៈសំខាន់នៃការប្រើប្រាស់ទឹកស្អាតជូនប្រជាពលរដ្ឋឱ្យបានទូលំទូលាយ ដើម្បីឱ្យគាត់យល់ហើយប្រើប្រាស់ទឹកស្អាតបានច្រើន។
- មានបុគ្គលិកឱ្យសមស្របនឹងការងារជាក់ស្តែង
- បង្កើនទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋាន
- ពង្រីកបណ្តាញបន្ថែម(អនុវត្តន៍តាមផែនការរបស់ខ្លួន)

**អនុសាសន៍៖ ប្រតិបត្តិករត្រូវ**

- ជីកស្រះ ស្តារប្រឡាយ ជីកអណ្តូង ដើម្បីបង្ការពេលមានបម្រែបម្រួលអាកាសធាតុ
- រាយការណ៍ទៅអាជ្ញាធរមូលដ្ឋាន ឬស្ថានប័នពាក់ព័ន្ធ ឱ្យបានទាន់ពេលវេលា ដើម្បីស្វែងរកដំណោះស្រាយ
- បង្កើនសមត្ថភាពចំណេះដឹងអំពីវិស័យទឹកស្អាត តាមរយៈសមាគម ឬស្ថានប័នផ្សេងៗដែលមានបទពិសោធន៍ផ្នែកទឹកស្អាត។
- អនុវត្តលក្ខខណ្ឌនៃប្រកាសអនុញ្ញាតឱ្យធ្វើអាជីវកម្មទឹកស្អាត(អាជ្ញាបណ្ណ) ដែលក្រសួងបានចេញជូន។

**៤.៣. មន្ទីរឧ.វ.ប.ន. ខេត្តបន្ទាយមានជ័យ**

ខេត្តបន្ទាយមានជ័យមានមូលដ្ឋានទឹកស្អាតចំនួន ២៩ស្ថានីយ កំពុងដំណើរការមាន ១៦ស្ថានីយទទួលបានប្រកាសអនុញ្ញាត ៣កំពុងដាក់ពាក្យសុំ ១សុំសិក្សាសមិទ្ធិលទ្ធភាព។ លើសពីនេះមានគម្រោង DBL ចំនួន៦ (ក្នុងនោះ ២មិនដំណើរការ) និងគម្រោង3i ចំនួន ៣កំពុងដំណើរការ)។ *សម្រាប់ព័ត៌មានលម្អិតមាននូវក្នុងស្លាយបទបង្ហាញ។*

Presentation-DISTI-BMC.pdf

**បញ្ហាប្រឈម**

- ខ្វះខាតប្រភពទឹក ជាពិសេសរដូវក្នុងប្រាំង
- ប្រតិបត្តិករមិនអនុវត្តតាមប្រកាសក្នុងការរៀបចំកិច្ចប្រជុំជាមួយឃុំ/សង្កាត់ប្រចាំឆ្នាំ
- ខ្វះឧបករណ៍ពិសោធន៍តាមស្ថានីយទឹកសម្រាប់ត្រួតពិនិត្យគុណភាព
- ខ្វះការសហការបញ្ជូនរបាយការណ៍ និងការជូនដំណឹងពេលពង្រីកបណ្តាញ

**អនុសាសន៍៖ ប្រតិបត្តិករត្រូវ**

- ជីកស្រះទឹកបន្ថែម ដើម្បីស្តុកទឹកទុកប្រើប្រាស់ក្នុងរដូវប្រាំង
- ជីកអណ្តូងថ្មី បង្កើនលទ្ធភាពទាញយកទឹកក្រោមដីសម្រាប់ប្រើប្រាស់
- ទិញទឹកពីឯកជន បង្កើតកិច្ចសហការជាមួយប្រតិបត្តិករឯកជនដើម្បីទិញទឹកបន្ថែម
- ធានាការផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋគ្រប់គ្រាន់ពេញមួយឆ្នាំ
- បង្កើតផែនការប្រជុំប្រចាំឆ្នាំជាមួយអាជ្ញាធរ
- ទិញឧបករណ៍ពិសោធន៍ដាក់តាមស្ថានីយនីមួយៗ សម្រាប់ត្រួតពិនិត្យគុណភាពទឹកស្អាតជាប្រចាំ
- ពង្រឹងតួនាទីសមាគម ក្នុងការចូលរួមដោះស្រាយវិវាទនានា
- លើកកម្ពស់ទំនាក់ទំនងជាមួយអាជ្ញាធរ

## ៤.៤. មន្ទីរឧ.វ.ប.ន. ខេត្តឧត្តរមានជ័យ

ខេត្តឧត្តរមានជ័យមានក្រុមហ៊ុន និងស្ថានីយទឹកស្អាតឯកជនចំនួន ៧ស្ថានីយ ក្នុងនោះមាន ១ស្ថានីយពុំទាន់មានប្រកាសអនុញ្ញាត តែបាននិងកំពុងផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋ។ *ព័ត៌មានលម្អិតមាននូវក្នុងស្លាយបទបង្ហាញ។*

Presentation-DISTI-OMC.pdf

**បញ្ហាប្រឈម**

- ប្រភពទឹកមិនមាននិរន្តរភាព ធ្វើឲ្យខ្វះប្រភពទឹកទាំងក្នុងរដូវប្រាំង និងរដូវវស្សា
- សមត្ថភាពផលិតទឹកស្អាតបានតិច ចំនួនអ្នកប្រើប្រាស់កាន់តែច្រើន ធ្វើឲ្យការផ្គត់ផ្គង់ទឹកមិនបានគ្រប់គ្រាន់
- បណ្តាញដាច់ធ្លុះធ្លាយច្រើនកន្លែង ធ្វើឱ្យទឹកគ្មានគុណភាព
- ដង់ស៊ីតេប្រជាជនមានកម្រិតទាប ការពង្រីកបណ្តាញមេត្រូវចំណាយច្រើន
- ខ្វះព័ត៌មានពីអាជ្ញាធរ និងមន្ទីរជំនាញពាក់ព័ន្ធក្នុងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ

**ដំណោះស្រាយ៖ ប្រតិបត្តិករត្រូវ**

- ធ្វើការស្នើសុំមកមន្ទីរជំនាញ និងអាជ្ញាធរពាក់ព័ន្ធដើម្បីជីកស្តារផ្ទៃអាងប្រភពទឹកបន្ថែម ឬមានស្រះឯកជន

- ធ្វើផែនការ និងអនុវត្តផែនការដើម្បីបង្កើនសមត្ថភាពផលិតទឹកស្អាតធ្វើយ៉ាងណាផ្គត់ផ្គង់ដល់អ្នកប្រើប្រាស់ឲ្យមាននិរន្តរភាព។
- សហការ និងទំនាក់ទំនងជាមួយអជ្ញាធរ និងអ្នកពាក់ព័ន្ធ
- ត្រូវមានផែនការច្បាស់លាស់ក្នុងការពង្រីកបណ្តាញចំពោះតំបន់សេវាកម្មដែលនៅសេសសល់
- ស្នើដល់អាជ្ញាធរ និងអ្នកពាក់ព័ន្ធផ្តល់ព័ត៌មានអំពីការអភិវឌ្ឍន៍នានាក្នុងភូមិសាស្ត្រ ជាពិសេសហេដ្ឋារចនាសម្ព័ន្ធឲ្យបានទាន់ពេលវេលាដល់សេវាករទឹកស្អាតជៀសវាងការខូចខាតបណ្តាញទឹកស្អាត។
- ស្នើដល់អាជ្ញាធរ និងអ្នកពាក់ព័ន្ធស្វែងយល់ពីគុណតម្លៃនៃទឹកស្អាត និងជួយផ្សព្វផ្សាយដល់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាននៃការប្រើប្រាស់សេវាទឹកស្អាត និងទឹកផៅ។

**៤.៥. មន្ទីរឧ.វ.ប.ន. ខេត្តព្រះវិហារ**

ខេត្តព្រះវិហារមានប្រតិបត្តិករចំនួន៦ ក្នុងនោះ ៣ស្ថានីយកំពុងដំណើការ និង៣ស្ថានីយកំពុងដំណើរការសាងសង់។ ក្នុងចំណោម ៥១ឃុំ/សង្កាត់ នៅមាន ២៨ឃុំ/សង្កាត់មិនទាន់មានប្រតិបត្តិករនៅឡើយ ដែលជាឱកាសសម្រាប់ប្រតិបត្តិករធ្វើការវិនិយោគលើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត។

**បញ្ហាប្រឈម**

- ប្រតិបត្តិករ ដែលទទួលបានអាជ្ញាបណ្ណហើយ មិនបានរួសរាន់សាងសង់ស្ថានីយទៅតាមផែនការអាជីវកម្មដែលខ្លួនបានដាក់ស្នើសុំទៅក្រសួងទេ(ខ្លះទុករហូតដល់៣ទៅ៥ឆ្នាំ)
- ប្រតិបត្តិករមួយចំនួនយឺតយ៉ាវក្នុងការរៀបបណ្តាញឲ្យបានពេញលេញក្នុងដែនសេវារបស់ខ្លួន និងមួយចំនួនទៀតមិនទាន់ធ្វើផែនទីតំបន់សេវាកម្មនៅឡើយ

**ដំណោះស្រាយ៖ ប្រតិបត្តិករត្រូវ**

- ត្រូវរួសរាន់អនុវត្តផែនការអាជីវកម្មរបស់ខ្លួនឲ្យបានទាន់ពេលវេលា ស្របតាមអាជ្ញាបណ្ណដែលខ្លួនបានទទួល
- រៀបចំបណ្តាញក្នុងដែនសេវាកម្មរបស់ខ្លួនឲ្យបានពេញលេញ ដើម្បីឱ្យប្រពលរដ្ឋមានទឹកស្អាតប្រើប្រាស់
- រិះរកគ្រប់មធ្យោបាយ ដើម្បីដឹកជញ្ជូនទឹកជូនប្រជាពលរដ្ឋ ដែលពុំទាន់មានទឹកស្អាតប្រើប្រាស់

**សំណូមពរ**

- ស្នើសមាគមបន្តកៀរគរប្រតិបត្តិករទឹកស្អាត មកចូលជាសមាជិកសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ស្របតាមអនុសាសន៍របស់ឯកឧតម្តរដ្ឋមន្ត្រីក្រសួងឧ.វ.ប.ន

**សំណួរ/សំណូមពរ សម្រាប់ខេត្តបន្ទាយមានជ័យៈ**

១. សុំឱ្យមន្ទីរពាក់ព័ន្ធនៅខេត្តបន្ទាយមានជ័យ ជូនដំណឹងអំពីការសាងសង់ផ្លូវដល់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត ដើម្បីបញ្ចៀសការខូចខាតបណ្តាញបំពង់ទឹកស្អាត។

**ចម្លើយ៖** តំណាងមន្ទីរអភិវឌ្ឍន៍ជនបទ បានឆ្លើយថា គ្រប់គម្រោងនៃការធ្វើផ្លូវ គឺមន្ទីរបានរាយការណ៍ជូនក្នុងកិច្ចប្រជុំក្រុមការងារទឹកស្អាត និងអនាម័យថ្នាក់ខេត្ត (WASH Provincial Working Group - PWG)។ ក្រុមការងារ PWG មានមន្ទីរឧ.វ.ប.ន.ជាសមាជិក។ ដូច្នេះប្រតិបត្តិករត្រូវមានផែនទីបណ្តាញទឹកស្អាត ចម្លងជូននៅអាជ្ញាធរមូលដ្ឋាន និងមន្ទីរពាក់ព័ន្ធ។

***ច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត មាត្រា២៤ កថាខណ្ឌទី២*** *«ច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាតបានកំណត់ថាកម្មសិទ្ធិករដើម្បីម្ចាស់ការឬអ្នកអនុវត្តគម្រោងសាងសង់ឬជួសជុលហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត*

*ត្រូវជូនដំណឹងមកក្រសួងទទួលបន្ទុកវិស័យទឹកស្អាត និងប្រតិបត្តិករដែលស្ថិតនៅក្នុងតំបន់ជួសជុលឬសាងសង់នោះជាលាយលក្ខណ៍អក្សរ ដោយបង្ហាញអំពីគម្រោងផែនការនៃការសាងសង់ ឬជួសជុលយ៉ាងតិច ៣០ ថ្ងៃមុនពេលចាប់ផ្តើមអនុវត្តគម្រោង»។*

### ៥. **បទបង្ហាញរបស់ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា ម.ក** (SME Bank)

ស្របតាមអនុសាសន៍របស់ **សម្តេច ហ៊ុន សែន** ធនាគារ SME ត្រូវបានបង្កើតឡើង និងទទួលបានអាជ្ញាបណ្ណជាធនាគារពាណិជ្ជ ពីធនាគារជាតិ នៅឆ្នាំ២០២០។ ធនាគារ SME ស្ថិតក្រោមអាណាព្យាបាលបច្ចេកទេស និងហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ធនាគារ SME មានទុនសរុបបច្ចុប្បន្ន ២២១លានដុល្លារអាមេរិក។ ធនាគារអាចផ្តល់កម្ចីរហូតដល់ ៣លានដុល្លារ រយៈពេល ៧ឆ្នាំសម្រាប់ទុនបង្វិល និងដល់រយៈពេល ១០ឆ្នាំសម្រាប់ទុនវិនិយោគ។ *សម្រាប់ព័ត៌មានលម្អិតមាននូវក្នុងស្លាយបទបង្ហាញ។*

## លក្ខណៈពិសេសនៃគម្រោងហិរញ្ញប្បទានដោយផ្ទាល់សម្រាប់ប្រតិបត្តិករទឹកស្អាតឯកជន (PWO)




| លក្ខណៈវិនិច្ឆ័យ | លក្ខខណ្ឌតម្រូវ |
|---|---|
| ទំហំឥណទាន | រហូតដល់ USD 3,000,000 ឬសមមូលជាប្រាក់រៀល |
| អត្រាការប្រាក់ក្នុងមួយឆ្នាំ | ចាប់ពី 5.00% (លម្អិតនៅស្លាយបន្ទាប់) |
| សោហ៊ុយរៀបចំឥណទាន | 0.5% (យកតែម្តងគត់) |
| រយៈពេលហិរញ្ញប្បទាន | រហូតដល់10ឆ្នាំ សម្រាប់ទុនវិនិយោគ ឬ 7ឆ្នាំសម្រាប់ទុនបង្វិល |
| ប្រភេទឥណទាន | ឥណទានមានកាលកំណត់ និង ឥណទានវិបារូបណ៍ |
| បំណុលធៀបនឹងទ្រព្យធានាសរុប | មិនលើសពី 80% សម្រាប់ប្លង់រឹង<br>ឬ មិនលើសពី 70% សម្រាប់ប្លង់ទន់ |

## អត្រាការប្រាក់ប្រចាំឆ្នាំសម្រាប់ប្រតិបត្តិករទឹកស្អាត

| បរិយាយ | អត្រាការប្រាក់ប្រចាំឆ្នាំសម្រាប់ប្រតិបត្តិករទឹកស្អាត |
|---|---|
| ឥណទានជាប្រាក់រៀល ៖ | |
| ម្ចាស់សហគ្រាសជាស្ត្រី | 5.00% |
| ម្ចាស់សហគ្រាសជាបុរស | 5.25% |
| ឥណទានជាប្រាក់ដុល្លារអាមេរិក ៖ | |
| ម្ចាស់សហគ្រាសជាស្ត្រី | 5.25% |
| ម្ចាស់សហគ្រាសជាបុរស | 5.50% |

អតិថិជននឹងទទួលបានការបញ្ចុះការប្រាក់ 0.25% សម្រាប់សមាជិកនៃដៃគូរសហការដែលបានចុះអនុស្សរណៈជាមួយធនាគារ សហគ្រាសធុនតូច និងមធ្យម កម្ពុជា

**សម្គាល់៖**

- ម្ចាស់សហគ្រាសជាស្ត្រី ឬបុរស គឺសំដៅលើម្ចាស់សហគ្រាសដែលមានការទទួលស្គាល់តាមផ្លូវច្បាប់ និងមានបញ្ជាក់នៅលើលិខិតចុះបញ្ជីអាជីវកម្ម ឬអាជ្ញាបណ្ណអាជីវកម្ម។
- អត្រាការប្រាក់ក្នុងតារាងខាងលើនឹងត្រូវអនុវត្តចំពោះតែសហគ្រាស ដែលបានចុះបញ្ជី ឬមានអាជ្ញាបណ្ណដែលកំពុងតែមានសុពលភាពជាធរមាន។
- ចំពោះសហគ្រាស ដែលមិនទាន់បានចុះបញ្ជី ឬមិនមានអាជ្ញាបណ្ណនឹងត្រូវអនុវត្តទៅតាមអត្រាការប្រាក់ដូចវិស័យធម្មតា។

PDF
Presentation-SME-SRP.pdf

## ៦. កិច្ចពិភាក្សាក្រុមតុមូលអំពីបញ្ហាប្រឈមដែលប្រតិបត្តិករជួបប្រទះតាមខេត្តនីមួយៗ

វាគ្មិនទាំងអស់ដែលអញ្ជើញមកពីបណ្តាមន្ទីរពាក់ព័ន្ធនានាត្រូវបានអញ្ជើញឡើងលើវេទិកាដើម្បីចូលរួមឆ្លើយ និងផ្តល់ជាអនុសាសន៍ជូនប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត។ ការពិភាក្សាបានប្រព្រឹត្តទៅដោយរលូន និងមានការចូលរួមលើកឡើងជាសំណួរ និងសំណូមពរក៏ដូចជាចម្លើយ និងអនុសាសន៍ តាមវិស័យ និងការទទួលខុសត្រូវរបស់មន្ទីរពាក់ព័ន្ធនីមួយៗ។ ខាងក្រោមជាលទ្ធផលសង្ខេបនៃកិច្ចពិភាក្សាតុមូលៈ

| ឈ្មោះខេត្ត | ដំណោះស្រាយ | អនុសាសន៍/សំណូមពរ |
|---|---|---|
| **<u>បញ្ហាប្រភពទឹកៈ</u>**<br>**១. តើត្រូវសហការបែបណាជាមួយ មន្ទីរធនធានទឹក និងឧតុនិយម ឬប្រតិបត្តិករឯកជន ដើម្បីធានាប្រភពទឹកគ្រប់គ្រាន់ដើម្បីនិរន្តរភាពនៃការផ្គត់ផ្គង់ទឹកស្អាត?** | | |
| **ខេត្តសៀមរាប**<br>– កង្វះខាតប្រភពទឹកសម្រាប់ផលិតនិងផ្គត់ផ្គង់ទឹកស្អាត<br>– ការប្រើប្រាស់ទឹកកើនឡើង ដោយសារមានការអភិវឌ្ឍន៍នានាដូចជា រោងចក្រ និងសហគ្រាសជាដើម។ | – ប្រតិបត្តិករត្រូវស្វែងរកទឹកបម្រុងដោយខ្លួនឯងពិសេសពេលសិក្សាសមិទ្ធិលទ្ធភាព។<br>– ប្រតិបត្តិករត្រូវជីកស្រះបម្រុងឯកជន ឬជីកអណ្តូងបន្ថែម វាជាទឹករបស់យើង។<br>– ឆ្លើយតបទៅនឹងការលើកឡើងថា បើជីកស្រះបម្រុងមានជម្រៅត្រឹម ៥ម៉ែត្រ នោះទឹកនឹងហួតតាមកំដៅថ្ងៃ ដែលធ្វើឱ្យទឹកមិនគ្រប់គ្រាន់។ ដូច្នេះប្រតិបត្តិករគួរស្នើសុំការអនុញ្ញាតឱ្យជីកស្រះបានដល់ជម្រៅពី១០ម៉ែត្រ ទៅ ១៥ម៉ែត្រ។ ក្នុងការងារនេះ មន្ទីរ ឧ.វ.ប.ន. មិនមានសិទ្ធិក្នុងការអនុញ្ញាតនោះទេ គឺមានតែក្រសួង/មន្ទីរ រ៉ែ និងថាមពលប៉ុណ្ណោះ។ | – ប្រតិបត្តិករ ស្នើសុំក្រសួង/មន្ទីរពាក់ព័ន្ធជួយសម្របសម្រួលអនុញ្ញាតឱ្យបាន ជីក ឬស្តារស្រះ ឬប្រឡាយដើម្បីពង្រីកប្រភពទឹកធានាដល់ការផ្គត់ផ្គង់ទឹកប្រកបដោយនិរន្តរភាព។<br>– ក្រសួងឬមន្ទីរពាក់ព័ន្ធទាំងអស់គួរបង្កើនកិច្ចសហការក្នុងស្វែងរកប្រភពទឹក។<br>– ប្រតិបត្តិករគួរស្វែងរកថវិកាស្តារប្រឡាយ និងទំនប់ទឹកផ្សេងៗ។<br>– ប្រតិបត្តិករ ឬភាគីពាក់ព័ន្ធគួរស្តារប្រឡាយដែលមានស្រាប់។ |
| **ខេត្តកំពង់ធំ**<br>– កង្វះខាតប្រភពទឹកនៅរដូវប្រាំងសម្រាប់ការផលិត និងផ្គត់ផ្គង់ទឹកស្អាត។ | – នៅកំពង់ធំ កាលរដូវប្រាំង ស្ថានីយទឹកស្អាតចុងដូង ស្ថានីយទឹកស្អាតបារាយ និងស្ថានីយទឹកស្អាតទ្រា មានការខ្វះខាតទឹក។ មានប្រឡាយមកពីទំនប់ ១មករា ដូច្នេះមន្ទីរធនធានទឹក និងឧតុនិយម បានសហការជាមួយអាជ្ញាធរ បានផ្តល់ជាម៉ាស៊ីនបូមទឹកដាក់ប្រឡាយចម្ងាយជាង ១០គម ចំនួន ២ថ្ងៃ ទើបមានទឹកទៅដល់ស្ថានីយ។ តែនៅតាមផ្លូវប្រជាពលរដ្ឋបានបូមស្ទាក់យកទឹក ទៅប្រើប្រាស់ និងធ្វើស្រែ។<br>– នៅរដូវប្រាំងអាជ្ញាធរ និងមន្ទីរពាក់ព័ន្ធបានសាកសួរទៅប្រតិបត្តិករដើម្បីដឹងថា តើស្ថានីយណាខ្លះដែលខ្វះទឹក ឬមិនអាចស្វែងរកប្រភពទឹកបម្រុងបាន ដើម្បីជួយដោះស្រាយបញ្ហាខ្វះទឹកនេះ។ | – ស្ថានីយណាដែលមានបញ្ហា នោះប្រតិបត្តិករអាចស្នើសុំមកមន្ទីរធនធានទឹក និងឧតុនិយមបាន មន្ទីរនឹងជួយសម្របសម្រួលជូន។<br>– ទឹកគឺសម្រាប់ទាំងអស់គ្នាមិនមែនសម្រាប់តែ ឧស្សាហកម្ម កសិកម្ម ឬទេសចរណ៍ទេ។ ដូច្នេះប្រតិបត្តិករអាចស្វែងរកប្រភពទឹក រួចស្នើមកមន្ទីរ ឬក្រសួងធនធានទឹក និងឧតុនិយម ដើម្បីជួយអន្តរាគមន៍ និងសម្របសម្រួលអស់ពីលទ្ធភាព។ |
| **ខេត្តព្រះវិហារ**<br>– ការចូលរួមសហការដោះស្រាយបញ្ហា | – មន្ទីរមិនមានលទ្ធភាពជីកអាងស្តុកទឹកថ្មីទេ យើងត្រូវសិក្សាពីប្រភពទឹកស្រាប់ដូចជា បឹង ទន្លេ អាងប្រឡាយ ដូច្នេះប្រតិបត្តិករត្រូវសិក្សាជាមុន។ | |

ជa

| | | |
|---|---|---|
| ប្រភពទឹក នៅមានកម្រិត<br>- ប្រឡាយមួយចំនួនមានការសាងសង់លំនៅដ្ឋាននៅពីលើអស់ហើយ មិនអាចឬពិបាកក្នុងការជីកឬស្តារឡើងវិញ។ | - មន្ទីរមិនមានសិទ្ធិកំណត់ជម្រៅជីក ឬស្តារ និងការចេញអាជ្ញាបណ្ណទេ មន្ទីរដែលមានសិទ្ធិ គឺមន្ទីររ៉ែ និងថាមពល។<br>- ក្រសួងធនធានទឹក និងឧតុនិយម កំពុងសិក្សាអំពីច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅព្រះរាជាណាចក្រកម្ពុជា។<br>- ការយកទឹកក្នុងដី លើដីទៅធ្វើអាជីវកម្មត្រូវសុំច្បាប់ពីអាជ្ញាធរទាំងអស់។ | |
| **ខេត្តបន្ទាយមានជ័យ**<br>- ខ្វះប្រភពទឹកនៅរដូវប្រាំង<br>- ទឹកក្រោមដីមានសារជាតុកំបោរ<br>- ប្រជាជនច្រើនប្រើប្រាស់ទឹកស្ទឹងមង្គលបុរី ប្រភពពីខេត្តប៉ៃលិន។<br>- ស្ទឹងសិរីសោភ័ណមិនមានប្រភពទឹកក្រៅពីទឹកភ្លៀង។<br>- ការប្រែប្រួលអាកាសធាតុក៏មានផលប៉ះពាល់ដល់របបទឹកភ្លៀង មានការប្រែប្រួលភ្លៀងតិចពេក<br>- ភ្លៀងខ្លាំងពេក ការកើនឡើងកម្តៅខ្លាំងពេក រំហួតខ្លាំងពេក បង្កទៅជាគ្រោះរាំងស្ងួត និងគ្រោះទឹកជំនន់។ | - មានការប្រើប្រាស់ប្រភពទឹកពីប្រទេសថៃ នៅផ្នែកខាងលិច ហូរតាមអូរចូលស្ទឹងសិរីសោភ័ណ និងផ្នែកខាងត្បូងប្រើប្រាស់ទឹកស្ទឹងមង្គលបុរី មានប្រភពទឹកមកពីខេត្តប៉ៃលិន។<br>- តម្រូវការត្រួតពិនិត្យគុណភាពទឹកជាប្រចាំ។<br>- រៀបចំផែនការប្រើប្រាស់ទឹកដោយមានសមធ៌ម។<br>- រដ្ឋបាលខេត្ត និងមន្ទីរធនធានទឹក និងឧតុនិយម កំពុងសិក្សាលទ្ធភាពស្តារស្ទឹង អូរ ប្រឡាយធំ តូច ស្វែងរកប្រភពទឹក ដើម្បីត្រៀមផ្គត់ផ្គង់ទឹកជូនប្រជាពលរដ្ឋ។<br>- រដ្ឋបាលខេត្ត និងមន្ទីរធនធានទឹក និងឧតុនិយម បានសហការជាមួយមន្ទីរជំនាញពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ ដើម្បីជួយសម្របសម្រួលអន្តរគមន៍សង្គ្រោះជាបន្ទាន់ ពេលវេលាប្រជាពលរដ្ឋខ្វះទឹកស្រោចស្រពផលដំណាំ និងទឹកប្រើប្រាស់ប្រចាំថ្ងៃ។ | - សូមប្រតិបត្តិករផលិតទឹកស្អាតសិក្សា អំពីប្រភពទឹក និងរៀបចំផែនការសុវត្ថិភាពទឹក ជីកស្រះ ខួងអណ្តូងដើម្បីធានាដល់ការផលិត និងផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋ។<br>- សូមប្រតិបត្តិករផលិតទឹកស្អាតសិក្សា អំពីកំណើនស្ថិតិប្រជាពលរដ្ឋប្រើប្រាស់ទឹក និងតម្រូវការប្រើប្រាស់ទឹកនៅតាមមូលដ្ឋាន។<br>- សូមប្រតិបត្តិករផលិតទឹកស្អាតរៀបចំផែនការប្រើប្រាស់ទឹក ចែកជូនរដ្ឋបាលខេត្ត មន្ទីរជំនាញពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន។ |
| **ខេត្តឧត្តរមានជ័យ**<br>- បញ្ហាដែលមន្ទីរបានលើកឡើងគឺ មន្ទីរពាក់ព័ន្ធខ្វះការទំនាក់ទំនងគ្នាទៅវិញទៅមក។ | - តាមក្រសួងស្ថាប័នមានការសិក្សាទៅលើការប្រើប្រាស់អាងទឹកមួយ គ្រាន់តែថា ការសិក្សានោះមិនទាន់មានភាគីចូលរួមគ្រប់គ្រាន់នៅឡើយ។<br>- ការគ្រប់គ្រងទឹកស្អាត និងប្រភពទឹករដ្ឋាភិបាលក៏គាំទ្រការសិក្សាឱ្យបានស៊ីជំរៅ ដើម្បីធ្វើយ៉ាងណាឱ្យមានប្រភពទឹកគ្រប់គ្រាន់។<br>- ប្រតិបត្តិករតែងមករកខាងមន្ទីរធនធានទឹក និងឧតុនិយមឱ្យជួយរកទឹកពេលខ្វះខាតទឹក ជាពិសេស | |

| | | |
|---|---|---|
| | មន្ទីរតែងតែជួយរកទឹកជូន មានពេលខ្លះដឹកទឹកជូនដល់កន្លែងដោយមិនគិតកម្រៃទៀតផង។<br>– នៅតាមទីជនបទ ប្រជាពលរដ្ឋប្រើទឹក ៥០លីត្រក្នុង១ថ្ងៃ ក្នុងមនុស្សម្នាក់ តែពេលរដូវខ្វះទឹកគឺ១ប៊ីដុង២០លីត្រប្រើ១គ្រួសារតែម្តង។<br>– នៅខាងឧត្តរមានជ័យ ប្រតិបត្តិករមានភាពវៃឆ្លាតដោយបានជីកស្រះបម្រុងទុក នៅរដូវវស្សាប្រើទឹករួម ដល់រដូវប្រាំងប្រើទឹកឯកជនខ្លួនឯង។<br>– គោលនយោបាយរបស់ក្រសួងធនធានទឹក និងឧតុនិយមគឺត្រូវស្តារអាងទឹក តែខ្វះថវិកា ឯកឧតម្តរដ្ឋមន្ត្រីក៏លើទឹកចិត្តវិស័យឯកជនក្នុងការស្តារប្រភពទឹកដែរ។ | |
| <u>**ការខូចខាតបណ្តាញផ្គត់ផ្គង់ទឹកស្អាត៖**</u><br>• **តើមន្ទីរមានយុទ្ធសាស្រ្តបែបណាដើម្បីកាត់បន្ថយការខូចខាតបណ្តាញនៅពេលសាងសង់ផ្លូវថ្នល់?**<br>• **តើស្ថានីយត្រូវធ្វើដូចម្តេចទើបទទួលបានសំណងលើផលប៉ះពាល់ និងតើនរណាជាអ្នកទទួលខុសត្រូវ?** | | |
| **ខេត្តសៀមរាប**<br>– ទឹកស្អាតពួក៖ មានការជូនដំណឹងហើយព្រមទាំងមានការសហការដែរ ប៉ុន្តែនៅតែមានការប៉ះបំពង់ទឹកស្អាត។<br>– ប្រជាពលរដ្ឋមិនបានដឹងអំពី ទីតាំងប្រព័ន្ធបណ្តាញទឹកស្អាតដែលធ្វើឱ្យជីកប៉ះបណ្តាញនៅពេលអាស្រ័យផលកសិកម្ម<br>**ខេត្តបន្ទាយមានជ័យ**<br>– ការធ្វើផ្លូវ លូ និងបណ្តាញទឹកកខ្វក់ប៉ះបណ្តាញទឹកស្អាត<br>– ការជូនដំណឹងអំពីការអភិវឌ្ឍន៍ផ្លូវថ្នល់ដាក់លូមិនបានជូនដំណឹងដល់ប្រតិបត្តិករទឹកស្អាតមុន។<br>**ខេត្តកំពង់ធំ**<br>– ការជីកដាច់បំពង់ទុយោទឹកស្អាត | ខាងក្រោមនេះជាដំណោះស្រាយដែលខេត្តទាំងអស់បានអនុវត្តកន្លងមក ហើយមានបទពិសោធន៍នៃការដោះស្រាយប្រហាក់ប្រហែលគ្នា៖<br>– ដើម្បីបញ្ចៀសការខូចខាតទុយោយើងមានការជូនដំណឹងអំពីការបើកការដ្ឋានរបស់យើងពីថ្ងៃណាដល់ថ្ងៃណា ដល់គ្រប់គាភីពាក់ព័ន្ធ ជាទូទៅយ៉ាងហោច ២សប្តាហ៍មុន (ដោយចម្លងជូនរដ្ឋបាលខេត្ត រដ្ឋបាលស្រុក ដើម្បីជូនជ្រាប សហការ និងផ្សព្វផ្សាយបន្ត។ គ្រប់ភាគីពាក់ព័ន្ធទាំងអស់ គួរមានកិច្ចសហការល្អ និងសម្របសម្រួល ពិសេសក្រុមហ៊ុនសាងសង់ផ្លូវ អាជ្ញាធរមូលដ្ឋាន ប្រតិបត្តិករ ប្រធានគណៈកម្មការគ្រប់គ្រងស្ថានីយទឹកសហគមន៍ អាជ្ញាធរអគ្គិសនី និងប្រជាពលរដ្ឋ ។<br>– អ្នកទទួលការងារតបណ្តាញទុយោ ត្រូវតែតាមលក្ខណៈបច្ចេកទេស (ការជូនដំណឹង ១ខែ ដូចជាយូរពេក)។<br>– ប្រជុំជាមួយភាគីពាក់ព័ន្ធពេលបើកការដ្ឋាន។ ទាំងអស់គ្នាត្រូវមានតំណាងរបស់ខ្លួននៅជាមួយយើងដើម្បីចាំជួយសម្របសម្រួល។<br><br>**មជ្ឍន្តិករ៖**<br>– តាមច្បាប់ការជូនដំណឹង១ខែ មុនមិនយូរទេ គួរជូនដំណឹងឱ្យបានយូរមុនដើម្បីអ្នកពាក់ព័ន្ធត្រៀមព្រោះគ្រប់ស្ថាប័នពាក់ព័ន្ធសុទ្ធមានផែនការ។<br>– កាលពីថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៥ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានផ្ញើលិខិតមួយទៅឯក | – សូមឱ្យមានការជូនដំណឹងជាមុនមកប្រតិបត្តិករស្របតាមច្បាប់ព្រោះពេលខ្លះជូនដំណឹងខ្លីពេក។<br>– ជាសំណូមពរនៅពេលកាយផ្លូវ តម្រូវឱ្យមានតំណាងប្រតិបត្តិករនៅទីនោះផង ដើម្បីត្រៀមបង្ការក្នុងករណីមានការខូចខាត រឺបាក់បែកបណ្តាញទុយោ ទឹកស្អាត ប្រតិបត្តិករអាចដោះស្រាយទាន់ពេលវេលា។<br>– ខាងការងារសាងសង់ផ្លូវក៏មានច្បាប់ដែរដីចំណីផ្លូវគេត្រូវយកធ្វើផ្លូវហើយដូច្នេះយើងទាំងអស់គ្នាត្រូវបង្កើតកិច្ចសហការគ្នា។<br>– បើមានការបើកការដ្ឋានសាងសង់ ឬជួសជុលផ្លូវសូមជូនដំណឹងឱ្យបានមួយខែមុខមកដើម្បីប្រតិបត្តិករបញ្ចៀស និងជួយសម្របសម្រួល។<br>– ប្រតិបត្តិករត្រូវមានផែនទីបណ្តាញនិងចម្លងជូនអាជ្ញាធរពាក់ព័ន្ធ (មន្ទីរ ឧ.រ.ប.ន. សាលាស្រុក និងសាលាឃុំ)<br>– សូមអោយមានតំណាងនាយកដ្ឋានបច្ចេកទេសក្រសួងពាក់ព័ន្ធ ចូលរួមប្រជុំក្នុងកិច្ចប្រជុំថ្នាក់តំបន់ផងដែរ<br>– សូមអោយប្រតិបត្តិករ ទំនាក់ទំនងជាមួយអាជ្ញាធរថ្នាក់ឃុំនិងភូមិ ។ |

| | | |
|---|---|---|
| – ប្រជាជនមានចំណេះដឹងនៅមានកម្រិតលើវិស័យទឹកស្អាតតាមបំពង់ (ជីកប៉ះទុយោ ...)<br>**ខេត្តឧត្តរមានជ័យ**<br>– កន្លងមកការជីកប៉ះពាល់ប្រព័ន្ធទឹកស្អាតមិនមានការសង តែក្រោយមកមានការសងវិញ ខាងសមាគមដឹងច្រើនពីរឿងនេះព្រោះធ្លាប់បានជួយអន្តរាគមន៍ដោះស្រាយជូនប្រតិបត្តិករជាសមាជិក។ | ឧត្តមរដ្ឋមន្ត្រីក្រសួងឧ.រ.ប.ន.អំពីបញ្ហាប៉ះពាល់ទុយោទឹកគឺបញ្ចៀសជាអតិបរមាកុំឱ្យប៉ះទុយោទឹក បើជៀសមិនផុតទេត្រូវមានសំណង។ | – រាល់សេចក្តីជូនដំណឹងដំណឹងអំពីការបើកការដ្ឋានសាងសង់ផ្លូវ សូមអាជ្ញាធរថ្នាក់ស្រុក និងឃុំជួយផ្សព្វផ្សាយបន្តអោយបានទូលំទូលាយ។ |
| **ការបំពានតំបន់អាជ្ញាបណ្ណ៖** | | |
| – មានការលក់ទឹកផៅ និងទឹកសហគមន៍នៅក្នុងតំបន់អាជ្ញាបណ្ណរបស់ប្រតិបត្តិករ | **មជ្ឈន្តិករ៖**<br>– យើងគួរជួយគ្នាបញ្ចៀសការបំពានតំបន់អាជ្ញាបណ្ណរវាងមន្ទីរឧ.រ.ប.ន. និងមន្ទីរអភិវឌ្ឍន៍ជនបទ ធ្វើយ៉ាងណាកុំឱ្យជាន់គ្នា ព្រោះបើជាន់ទៅយើងខាតទាំងអស់គ្នា។<br>– ពេលខ្លះការទទួលបានអាជ្ញាបណ្ណត្រូវប្រើរយៈពេលយូរ តែមុនពេលក្រសួងចេញអាជ្ញាបណ្ណ២០ឆ្នាំ នោះក្រសួងបានចេញព្រាងប្រកាស ២០ថ្ងៃ យកទៅបិទនៅសាលាឃុំ បើមេឃុំប្រាប់បញ្ជាក់ថាគេថាមានទឹកសហគមន៍ធ្វើហើយ នោះក្រសួងអាចកាត់ចេញនូវតំបន់ជាក់លាក់នោះដែរ។ | – សំណូមពរ សុំឱ្យក្រសួង/មន្ទីរឧ.រ.ប.ន.រៀបចំបទបង្ហាញអំពីនីតិវិធីក្នុងការទទួលបានអាជ្ញាបណ្ណ និងខ្លឹមសាររបស់អាជ្ញាបណ្ណ ជូនដល់មន្ទីរអភិវឌ្ឍន៍ជនបទ និងមន្ទីរពាក់ព័ន្ធផ្សេងទៀតក្នុងខេត្ត និងអាជ្ញាធរថ្នាក់ក្រោមជាតិ។ |
| **បញ្ហាផ្សេងៗ** | | |
| – ទឹកក្រោមដីមានកំបោរច្រើន<br>– ខ្វះបច្ចេកទេសល្អក្នុងការលាងសម្អាតបំពង់មេឱ្យបានស្អាតល្អ។ | – ប្រតិបត្តិករត្រូវយកសំណាកប្រភពទឹកអណ្តូងនោះទៅមន្ទីរពិសោធន៍ថ្នាក់ជាតិ ដើម្បីវិភាគមើលកម្រិតនៃជាតិកំបោរដែលមាននៅក្នុងទឹកនោះ។ បើស្ថិតនៅក្នុងកម្រិតលើស ប្រតិបត្តិករអាចបូមទឹកអំពីអណ្តូងដាក់ក្នុងស្រះជីកសិនមុន វាអាចដកជាតិកាបោបានខ្លះ។ ម្យ៉ាងទៀត ប្រតិបត្តិករអាចចំណាយថវិកាច្រើនក្នុងការរៀបចំអាងដកជាតិកំបោរ។<br>– បិទវ៉ានតាមប្លុកនីមួយៗ រួចបង្កើនសម្ពាធ និងដាក់ក្លរដើម្បីលាង ទុករយៈពេល៣០ទៅ៤០នាទីដើម្បីក្លរធ្វើការសម្លាប់មេរោគ រួចបង្ហូរទឹកចោលនៅចុង | – បើលទ្ធផលវិភាគគុណភាពទឹកបង្ហាញថា លើសកម្រិតអនុញ្ញាតនោះប្រតិបត្តិករដាច់ខាតត្រូវបិទអណ្តូងនោះចោល ស្វែងរកប្រភពទឹកផ្សេងៗ។<br>– ប្រតិបត្តិករត្រូវតែរៀបចំផែនការថែទាំ និងសម្អាតប្រព័ន្ធបណ្តាញឱ្យបានទៀងទាត់។ |

| | | |
|---|---|---|
| | ទុយោ។ ដើម្បីរក្សាទុយោមេឱ្យបានស្អាតល្អ ប្រតិបត្តិករត្រូវដាក់ផែនការបើកវ៉ានបង្ហូរទឹកនៅចុងបណ្តាញចេញ តាមស្ថានភាពជាក់ស្តែងរបស់បណ្តាញ។ | |

## ៧. កម្មវិធីបិទអង្គប្រជុំ

**លោក លឹម មិញ នាយកប្រតិបត្តិ** សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា បានថ្លែងអំណរគុណដល់រដ្ឋបាលខេត្តសៀមរាបចំពោះការគាំទ្រ និងកិច្ចសហការយ៉ាងកក់ក្តៅ មន្ទីរពាក់ព័ន្ធទាំងប្រាំខេត្ត ដែលបានចូលរួមយ៉ាងសកម្ម តំណាងអង្គការ Water.org ថ្នាក់ដឹកនាំ និងសមាជិកក្រុមប្រឹក្សាភិបាល ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន បុគ្គលិកសមាគម ព្រមទាំងបណ្តាក្រុមហ៊ុនទាំងអស់ ដែលបានជួយឧបត្ថម្ភកិច្ចប្រជុំថ្នាក់តំបន់ក្នុងខេត្តសៀមរាប ដែលធ្វើឱ្យកិច្ចប្រជុំនេះប្រព្រឹត្តទៅតាមផែនការដែលបានគ្រោងទុក។ ទន្ទឹមគ្នានេះដែរ លោកក៏បានប្រកាសបិទកិច្ចប្រជុំថ្នាក់តំបន់នៅខេត្តសៀមរាប និងជូនពរសូមឱ្យការធ្វើដំណើរវិលត្រឡប់ទៅវិញប្រកបដោយ សេចក្តីសុខ និង សុវត្ថិភាពទាំងអស់គ្នា។

សុក្រ ១០រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៥

**បានពិនិត្យ និងឯកភាព**

Cambodian Water Supply Association C.W.A

**លឹម មិញ**

**អ្នកធ្វើកំណត់ហេតុ**

Chanda

**ផង់ ចិន្តា**